# មាតិកាមេរៀន


១ ការរៀបចំស្រែ ........ 3

១.១ ការជ្រើសរើសទីតាំង ........ 3

១.២ ទំហំស្រែ ........ 3

១.៣ ជម្រៅស្រែ ........ 3

១.៤ បាតស្រែ ........ 3

១.៥ ប្រភេទដីសំរាប់ប្រើប្រាស់រៀបចំស្រែ ........ 4

១.៥.១ ដីសរីរាង្គ ........ 4

១.៥.២ អជីសរីរាង្គ (ជីគីមី) ........ 4

២. អនុវត្តន៍រៀចំស្រែ ........ 4

២. ១ ករណីថ្មី ........ 4

២. ២ ករណីកសិករធ្លាប់ចិញ្ចឹម(មានស្រែះស្រាប់) ........ 5

២. ២.១ តម្រូវការសម្ភារៈ ........ 5

២. ២.២ បរិមាណជីធម្មជាតិ និង ជីគីមី ........ 6

វិធីសាស្រ្តបាចស្ងួត ........ 6

វិធីសាស្រ្តបាចរាវ ........ 6

៣ ការដាក់កូនត្រីចិញ្ចឹម ........ 8

៣.១ ប្រភេទត្រីដាក់ចិញ្ចឹម ........ 8

៣.២ លក្ខណៈជីវសាស្រ្ត និងចរឹកស៊ីចំណី ........ 8

៣.២.១ លក្ខណៈជីវសាស្រ្តត្រីឆ្ពិន ........ 8

៣.២.២ លក្ខណៈជីវសាស្រ្តត្រីទីឡាព្យា ........ 9

៣.២.៣ លក្ខណៈជីវសាស្រ្តត្រីកាបសាមញ្ញ ........ 9

២.២.៤ លក្ខណៈជីវសាស្រ្តត្រីកាបឥណ្ឌា ........ 9

៣.៣ ការត្រួតពិនិត្យគុណភាពកូនត្រីពូជ ........ 9

៣.៤ ដង់ស៊ីតេត្រីដាក់ចិញ្ចឹម ........ 10

៣.៥ ចំនួនកូនត្រីដាក់ចិញ្ចឹម ........ 10

៣.៦ ទំហំកូនត្រីសមស្រប ....................................................................... 10
៣.៧ ការដាក់ជីក្រោយដាក់ចិញ្ចឹម ....................................................................... 11
៣.៧.១ ជីធម្មជាតិ ....................................................................... 11
៣.៧.១.១ ការជីករណ្ដៅជី ....................................................................... 11
៣.៧.១.២ ការរៀបចំកំប៉ុស្តក្នុងរណ្ដៅជី ....................................................................... 11
៣.៧.២ ជីគីមី ....................................................................... 12
៤ ការគ្រប់គ្រងគុណភាពទឹក ....................................................................... 12
៤.១ ការពិនិត្យពណ៌ទឹកដោយភ្នែកទទេ ....................................................................... 12
៤.២ ការពិនិត្យគុណភាពទឹកដោយប្រើឧបករណ៍វាស់ PH ....................................................................... 13
៤.៣ ការផ្ដល់ចំណី ....................................................................... 13
៤.៣.១ ចំណីធម្មជាតិ ....................................................................... 13
៤.៣.២ ចំណីបន្ថែម ....................................................................... 14
៥ តាមដានការលូតលាស់ត្រី ....................................................................... 15
៥.១ ត្រៀមរៀបចំសំភារៈ ....................................................................... 15
៥.២ ការយកសំណាក និង វាស់ថ្លឹងត្រី ....................................................................... 15
៦ ការប្រមូលផលត្រី និងទីផ្សារ ....................................................................... 17
៦.១ ការប្រមូលផលរំលោះ ....................................................................... 17
៦.២ ការប្រមូលផលសរុប ....................................................................... 17
៦.៣ បច្ចេកទេសប្រមូលផល ....................................................................... 17

# ការណែនាំបច្ចេកទេស ធ្វើបង្ហាញអំពីការចិញ្ចឹមត្រីចំរុះ

## ១ ការរៀបចំស្រះ

### ១.១ ការជ្រើសរើសទីតាំង

ស្រះជិតផ្ទះងាយស្រួលគ្រប់គ្រង ជិតប្រភពទឹក ស្ថិតនៅក្នុងតំបន់ដី ល្បាយដីឥដ្ឋ ស្ថិតនៅទីវាលស្រឡះមិនលិចទឹកនៅរដូវវស្សា ស្រះមានទីតាំងជាប់ស្រែកាន់តែល្អប្រសើរ នៅឆ្ងាយពីតំបន់ប្រើប្រាស់ថ្នាំពុលកសិកម្ម

### ១.២ ទំហំស្រះ

- ស្រះតូច ឬធំសុទ្ធតែចិញ្ចឹមត្រីបានទាំងអស់
- ករណីស្រះធំទូលាយនោះកាន់តែល្អ ពីព្រោះថា ៖
- អាចរក្សាបានយូរ
- មិនងាយប្រែប្រួលសីតុណ្ហភាពទឹក
- សំបូរចំណីធម្មជាតិ
- បរិមាណអុកស៊ីសែនរលាយក្នុងទឹកមានកំរិតខ្ពស់ ដែលជាកត្តាធ្វើឱ្យចំណីធម្មជាតិ កកើត លូតលាស់បានល្អ និងទិន្នផលត្រីខ្ពស់។
- ស្រះសមស្របគួរមានទំហំពី ៥០០ - ១០០០ម$^{២}$ សម្រាប់ការចិញ្ចឹមបង្ហាញស្រះទំហំ (២០មx ២៥ម)

### ១.៣ ជម្រៅស្រះ

- បាតស្រះជាកត្តាកំណត់នៃគុណភាពទឹក
- ជាកត្តាធ្វើឱ្យរុក្ខជាតិបួង់តុង និងសត្វល្អិតបួង់តុងលូតលាស់បានល្អដែលជាចំណីធម្មជាតិដ៏សំខាន់របស់ត្រី
- តែករណីបាតស្រះមានភក់ច្រើនជាបញ្ហាធ្វើឱ្យងាយស្អុយ និងត្រី អាចមានជំងឺផ្សេងៗ
- ផ្ទុយទៅវិញ បើបាតស្រះមានភក់តិចឬគ្មានភក់នោះបណ្តាល ឱ្យស្រះ រក្សាទឹកមិនបានយូរ និងចំណីធម្មជាតិមិនសូវលូត លាស់បានល្អ
- បាតស្រះដែលមានលក្ខណៈល្អសមស្របសំរាប់ចិញ្ចឹមត្រីគួរមានភក់ជម្រៅពី២០ស.ម-៣០ស.ម

### ១.៤ បាតស្រះ

- បាតស្រះជាកត្តាកំណត់នៃគុណភាពទឹក
- ជាកត្តាធ្វើឱ្យរុក្ខជាតិបួង់តុង និងសត្វល្អិតបួង់តុងលូតលាស់បានល្អដែលជាចំណីធម្មជាតិដ៏សំខាន់របស់ត្រី
- តែករណីបាតស្រះមានភក់ច្រើនជាបញ្ហាធ្វើឱ្យងាយស្អុយ និងត្រី អាចមានជំងឺផ្សេងៗ
- ផ្ទុយទៅវិញ បើបាតស្រះមានភក់តិចឬគ្មានភក់នោះបណ្តាល ឱ្យស្រះ រក្សាទឹកមិនបានយូរ និងចំណីធម្មជាតិមិនសូវលូត លាស់បានល្អ
- បាតស្រះដែលមានលក្ខណៈល្អសមស្របសំរាប់ចិញ្ចឹមត្រីគួរមានភក់ជម្រៅពី២០ស.ម-៣០ស.ម

- ត្រូវមានលក្ខណៈរាបស្មើ និង ចោទឆ្ពោះ រកទ្វារទឹកបញ្ចេញចោល។

### ១.៥ ប្រភេទជីសំរាប់ប្រើប្រាស់រៀបចំស្រះ

#### ១.៥.១ ជីសរីរាង្គ

- លាមកសត្វ(គោ ជ្រូក មាន់ ទា ។ល។ )

- ជីបៃតង(ទន្ទ្រាំងខែត្រ)

-កាកសំណល់បន្លែបៃតង

#### ១.៥.២ អជីសរីរាង្គ (ជីគីមី)

ដេអាប៉េ DAP) និង អ៊ុយរ៉េ( UREA )

# ២. អនុវត្តន៍រៀបចំស្រះ

## ២. ១ ករណីថ្មី

- របៀបជីកស្រះគឺត្រូវ
  - ✓ កំណត់ទំហំស្រះ
  - ✓ លក្ខណៈភ្លឺស្រះ
  - ✓ កំណត់ទំហំខ្នងភ្លឺ
  - ✓ ជើងទេរភ្លឺស្រះ
  - ✓ ជើងទេរស្រះ និង
  - ✓ កំពស់ខ្នងភ្លឺស្រះ។
- ស្រះសមស្របគួរមានទំហំពី ៥០០ - ១០០០ម$^{២}$



របៀបជីកតាមលក្ខណៈបច្ចេកទេស

**តារាង(១)កំរិតជើងទេរភ្លឺអាស្រ័យប្រភេទដី**

| ប្រភេទដី | កំរិតជើងទេរចាស់ | កំរិតជើងទេរស្រះថ្មី |
|---|---|---|
| ល្បាយដីឥដ្ឋ | ១ | ១.៥០-២.0 |
| ល្បាយដីឥដ្ឋទាប | ១.២៥ | ១.៥០-២.0 |
| ល្បាយដីឥដ្ឋលាយខ្សាច់/គ្រួស | ១.៥០ | ២.0-២.៥០ |
| ល្បាយខ្សាច់លាយដីឥដ្ឋ | ១.៥០-២.0 | ២.៥០-៣.0 |

**តារាង(២)កំរិតកំពស់ខ្នងភ្លឺស្រះ**

| ប្រភេទភ្លឺស្រះ | កំពស់ខ្នងភ្លឺ(សម) |
|---|---|
| ភ្លឺស្រះបំប៉ន | ៤០ - ៥០ |
| ភ្លឺស្រះត្រីមេពូជ/ត្រីសាច់ | ៥០ - ៦០ |
| ភ្លឺទំនប់កសិដ្ឋាន | ៥០ - ៤០ |

**តារាង(៣)ការកំណត់ទំហំខ្នងភ្លឺ**

| ប្រភេទភ្លឺស្រះ | ផ្លូវដឹកជញ្ជូន (ម) | ផ្លូវដើរ (ម) |
|---|---|---|
| ភ្លឺរួម | ៥-៦ | ៣-៤ |
| ភ្លឺស្រះ | ៤ | ៣ |
| | | |

## ២. ២ ករណីស្រះចាស់

- **ការរៀបចំស្រះមុនដាក់កូនត្រីចិញ្ចឹម** គឺការសំអាតសារធាតុសរីរាង្គបាតស្រះ បំបាត់សារធាតុពុល បំបាត់ឧស្ម័នពុល សំលាប់ពពួកមេរោគដែលបង្កឱ្យត្រីមានជំងឺ សំលាប់ត្រីកាច ស្តារភក់បាតស្រះ សំអាតស្មៅនិងរុក្ខជាតិនៅជុំវិញភ្លឺស្រះ និង បង្កើតលក្ខខ័ណ្ឌសមស្របដល់ ការលូតលាស់របស់សត្វនិងរុក្ខជាតិប្លង់តុងដែលជាចំណី ធម្មជាតិរបស់ត្រី។

### ២. ២.១ តម្រូវការសម្ភារៈ

- ម៉ាស៊ីនបូមទឹក ទុយោ
- ធុង ស្បៃ
- កំបោរស ជី UREA/DAP
- ជីសរីរាង្គ (ជីលាមកគោ...)

## ២. ២.២ បរិមាណជីធម្មជាតិ និង ជីគីមី

កំបោរស សំលាប់ពពួកមេរោគដែលបង្កឱ្យត្រីមានជំងឺ សំលាប់ត្រីកាច ។

- កំបោរស- ១០-១៥គក្រ/១០០ម²
- អ៊ុយរ៉េ និង ដេអាប៉េ ១គក្រ(អ៊ុយរ៉េ ០.៧គក្រ + ដេអាប៉េ ០. ៣គក្រ) /១០០ម²
- ជីលាមគោ ៥០-៦០គក្រ/១០០ម²

## វិធីសាស្ត្របាចស្ងួត

បាចផ្ទាល់ ដោយប្រើស្រោមដៃ និងពាក់ម៉ាសការពារត្រូវបាចពីលើទិសខ្យល់បក់ដើម្បីការពារសុខភាព។ បរិមាណកំបោរស ១០-១៥គក្រ/១០០ម² ការបាចនេះធ្វើយ៉ាងណា អោយបានសព្វផ្ទៃស្រះ រួចទុកហាលថ្ងៃរយៈពេលពី១-៣ថ្ងៃ។ បន្ទាប់មកទើបបាចជីលាមកគោទ្រាប់បាតស្រះ។





**សកម្មភាពរៀបចំ កំបោរស្ងួត ដើម្បីសំលាប់ត្រីកាច និងពពួកសត្វចង្រៃ**

## វិធីសាស្ត្របាចរាវ

ប្រើធុង ចានដែក ពាង ឬខាប់ ដើម្បីលាយកំបោរជាមួយនិងទឹកដោយដាក់កំបោរ ប្រមាណ៧គក្រ លាយទឹកអោយពេញធុងស្តិចត្រូលរួចយកផ្តិលឬបោយដងបាចអោយសព្វទៅលើផ្ទៃស្រះរួចទុកហាលថ្ងៃរយៈពេលពី២-៣ថ្ងៃ បន្ទាប់បញ្ជូកទឹក ពី ២០-៣០ សម ដោយមានច្រោះស្បៃ ។





**សកម្មភាពលាយកំបោរ និងទឹក ដើម្បីសំលាប់ត្រីកាច និងពពួកសត្វចង្រៃ**

## ជីលាមកគោ

បរិមាណប្រើប្រាស់អាស្រ័យប្រភេទស្រះចាស់ ឬស្រះថ្មី (សូមមើលតារាង៤) លាមកគោផ្តល់សារធាតុចិញ្ចឹម(អាសូតនិងផូស្វ័រ)បង្កើតការលូតលាស់របស់សត្វនិងរុក្ខជាតិប្លង់តុងដែលជាចំណី ធម្មជាតិរបស់ត្រី។ ជីលាមកគោត្រូវបាចក្រោយកកំបោររយៈពេល ៣ថ្ងៃយ៉ាងយូរ បន្ទាប់ត្រាំវាទុករយៈពេល ៤-៥ ថ្ងៃ រួចបញ្ចូលទឹកជំរៅ ពី ១-១.៥ ម៉ែត្រ។





សកម្មភាពបាចជីលាមកគោក្រាលបាតស្រះដើម្បីបង្កើតចំណីធម្មជាតិ

- **ជី UREA/DAP ៥គក្រ/១០០ម$^{២}$ ៖**

សកម្មភាពនេះត្រូវធ្វើបន្ទាប់ពីបាចជីលាមកគោរួចការបាចជីអ៊ុយរ៉េ/ដេអាប៉េ គឺត្រូវលាយទឹកអោយរលាយគ្រាប់អស់សិនទើបអាចបាចចូលទៅក្នុងស្រះ។ ជីអ៊ុយរ៉េ/ដេអាប៉េ ផ្តល់សារធាតុចិញ្ចឹម(អាសូតនិងផូស្វ័រ)បង្កើតការលូតលាស់របស់សត្វនិងរុក្ខជាតិប្លង់តុងដែលជាចំណី ធម្មជាតិរបស់ត្រី។





សកម្មភាពថ្លឹងជី UREA/DAP ដើម្បីបាចលើផ្ទៃស្រះដើម្បីបង្កើតចំណីធម្មជាតិ

**តារាង(៤) បរិមាណជី និងកំបោរ ដែលអាចប្រើប្រាស់ ក្នុងពេលរៀបចំស្រះចិញ្ចឹមត្រី**

| **បរិយាយ** | **ស្រះចាស់(១០០ម$^{២}$)** | **ស្រះថ្មី (១០០ម$^{២}$)** |
|---|---|---|
| កំបោរ | ៥ ទៅ ១០ គីឡូក្រាម | ១០ ទៅ ១៥ គីឡូក្រាម |
| លាមកគោ ឬក្របីសើម | ៦០ ទៅ ៨០ គីឡូក្រាម | ៨០ ទៅ ១០០ គីឡូក្រាម |

| | | |
|---|---|---|
| លាមកមាន់ ទាសើម | ១០ ទៅ ១៥ គីឡូក្រាម | ១៥ ទៅ ២០ គីឡូក្រាម |
| លាមកជ្រូកសើម | ២០ ទៅ ៣៥ គីឡូក្រាម | ២៥ ទៅ ៤០ គីឡូក្រាម |
| ស្លឹកទន្រ្ទានខែត្រ | ២០ ទៅ ៣០ គីឡូក្រាម | ៣០ ទៅ ៤០ គីឡូក្រាម |
| ដេ អា ប៉េ | ០.៣  គីឡូក្រាម | ១ គីឡូក្រាម |
| អ៊ុយរ៉េ | ០.៧  គីឡូក្រាម | ២ គីឡូក្រាម |

ប្រភពៈ បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈ គ្រួសារ (នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម)

## ៣ ការដាក់កូនត្រីចិញ្ចឹម

ការដាក់ត្រីចិញ្ចឹម ត្រូវអនុវត្តក្រោយការរៀបចំស្រះរយៈពេល ១សប្តាហ៏

### ៣.១ ប្រភេទត្រីដាក់ចិញ្ចឹម

- ប្រភេទងាយស្រួលចិញ្ចឹម
- ងាយរកពូជមកចិញ្ចឹម
- ធន់នឹងជំងឺ
- ស៊ីចំណីធម្មជាតិ និងចំណីបន្ថែមដែលអាចរកបាន
- មានតម្លៃក្នុងទីផ្សារ ប្រជាជននិយមបរិភោគ
-

### ៣.២ លក្ខណៈជីវសាស្រ្ត និងចរឹកស៊ីចំណី


ត្រីឆ្ពិន


ត្រីទីឡាព្យា


ត្រីកាបសាមញ្ញ


ត្រីកាបឥណ្ឌា

#### ៣.២.១ លក្ខណៈជីវសាស្រ្តត្រីឆ្ពិន

ជាត្រីធម្មជាតិរស់នៅប្រទេសដែលមានព្រំប្រទល់ជាប់នឹងដងទន្លេមេគង្គ ដែលមានចរន្តទឹកហូរដូចជា ទន្លេ ស្ទឹង បឹង ស្រះជាដើម ដែលមាន pH ពី៦,៥ - ៧,៥ ។

-ត្រីឆ្ពិន រស់នៅស្រទាប់ កណ្តាល និងលើ ។ ស៊ីចំណីចំរុះដូចជា ត្រកួន ចកបាយទា ពងទឹក បាយ កន្ទំថេត កន្ទក់ ចុងអង្ករ ដំឡូងជ្វា កណ្តៀរ លាមកសត្វ។ល។

-ត្រីញី មានទំហំធំជាង ត្រីឈ្មោល។ ជាប្រភេទត្រីពងអណ្តែត វាទំលាក់ ពងក្នុងស្រះឬកន្លែងដែលមានចរន្តទឹកហូរ។

-រយពេលចិញ្ចឹមមួយឆ្នាំបានទំងន់ពី ៣០០-៦០០ក្រាមក្នុង១ក្បាល

-វាអាចបន្តពូជបានពេលមានអាយុ ៨ ខែ ឡើងទៅ

### ៣.២.២ លក្ខណៈជីវសាស្ត្រត្រីទីឡាព្យា

ជាត្រីដែលមានប្រភពមកពីអាហ្វ្រិកខាងជើង រស់នៅតំបន់ទឹកសាប និងអាចរស់នៅទឹកភ្លាវ ។

- រស់នៅស្រទាប់លើ កណ្ដាល និងបាត។ ស៊ីចំណីចំរុះដូចជា រុក្ខជាតិក្នុងទឹក ស្លែ ជន្លេន កណ្ដៀរ ចូលចិត្ត រស់នៅតាមមាត់ស្រះដែលមានទឹករាក់ ។

-រស់នៅក្នុងមជ្ឈដ្ឋានទឹកដែលមាន pH ពី ៤ - ៩ និងសីតុណ្ហភាព ១៤-៤០ អង្សាសេ

-ស៊ីចំណីបន្ថែម ដូចជាកន្ទក់ ចុងអង្ករ ពោត សណ្ដែក កាកសំណល់ផ្ទះបាយជាដើម

-រយៈពេលចិញ្ចឹម១ឆ្នាំបានទំងន់ពី ៣០០-៥០០ក្រាមក្នុង១ក្បាល

- វាអាចបន្តពូជបានពេលមានអាយុ៤ ខែឡើងទៅ ។ បន្តពូជដោយធម្មជាតិបានរហូតដល់ ១១ដងក្នុងមួយឆ្នាំ។

### ៣.២.៣ លក្ខណៈជីវសាស្ត្រត្រីកាបសាមញ្ញ

ត្រីកាបសាមញ្ញ ជាត្រីដែលមានប្រភពមកពីប្រទេសចិន រស់នៅតំបន់ទឹកសាប។

-រស់នៅស្រទាប់ បាត ស៊ីចំណីចំរុះដូចជា កូនខ្យង ខ្ចៅ ក្ដាម ជន្លេន កណ្ដៀរ សត្វល្អិត រុក្ខជាតិក្នុងទឹក ស៊ីចំណីបន្ថែម ដូចជាកន្ទក់ ចុងអង្ករ ពោត សណ្ដែក កាកសំណល់ផ្ទះបាយជាដើម ។

-រស់នៅក្នុងមជ្ឈដ្ឋានទឹកដែលមាន pH ពី៥,៥ - ៨,៥ និងសីតុណ្ហភាព២០ - ៣០ អង្សាសេ

-ជាប្រភេទត្រីពងតោង វាអាចបន្តពូជបានពេលមានអាយុ៨ ខែ ឡើងទៅ (ដោយប្រើចរន្តទឹកភ្លៀង)

-រយៈពេលចិញ្ចឹមមួយឆ្នាំបានទំងន់ពី ៥០០-១០០០ក្រាមក្នុង១ក្បាល

### ២.២.៤ លក្ខណៈជីវសាស្ត្រត្រីកាបឥណ្ឌា

ជាត្រីដែលមានប្រភពមកពីប្រទេសក្រៅ រស់នៅតំបន់ទឹកសាប។

-រស់នៅស្រទាប់ បាត ស៊ីចំណីចំរុះដូចជា សត្វល្អិតក្នុងទឹក ចកបាយទា រុក្ខជាតិក្នុងទឹក ។ល។

-រស់នៅក្នុងមជ្ឈដ្ឋានទឹកដែលមាន pH ពី៥,៥ - ៨,៥ និងសីតុណ្ហភាព២០ - ៣០ អង្សាសេ

-ស៊ីចំណីបន្ថែម ដូចជាកន្ទក់ ចុងអង្ករ ពោត សណ្ដែក កាកសំណល់ផ្ទះបាយជាដើមវាអាចបន្តពូជបានពេល មានអាយុ១,៥ ឆ្នាំឡើងទៅ

-រយពេលចិញ្ចឹមមួយឆ្នាំបានទំងន់ពី ៥០០-៧០០ក្រាមក្នុង១ក្បាល ។

## ៣.៣ ការត្រួតពិនិត្យគុណភាពកូនត្រីពូជ

- ជាកត្តាសំខាន់ ព្រោះថា កាលណាយើងជ្រើសរើសគុណភាពកូនត្រីពូជបានល្អនោះត្រីចិញ្ចឹមធំធាត់លឿន និងទទួលបានទិន្នផលត្រីខ្ពស់ ។

**លក្ខណៈកូនត្រីពូជល្អ ៖**

- សកម្មភាពហែលរហ័សរហួន
- ពេលឃើញមនុស្ស ឬ សត្រូវ កូនត្រីមានសកម្មភាពហែលគេចខ្លួយ៉ាងលឿនចុះទៅបាតស្រះ
- ករណីហែលផ្តុំក្បាលគ្នានៅត្រង់ចំណុចកណ្ដាលស្រះមុនពេលថ្ងៃរះ និង ក្រោយថ្ងៃរះហែលចុះទៅស្រទាប់ទឹក បាតស្រះ

- ពេលដាក់ចំណីកូនត្រីបញ្ចេញសកម្មភាពដណ្តើមគ្នាស៊ី
- កូនត្រីមានពណ៌សំបុរភ្លឺថ្លា និងនៅលើស្រកាសំបូរ សារធាតុរំអិល ព្រមទាំងចូលចិត្តហែលបញ្ច្រាស់ចរន្តទឹក ។

## ៣.៤ ដង់ស៊ីតេត្រីដាក់ចិញ្ចឹម

- ប្រភេទត្រីទាំងនេះ ត្រូវបានគេដាក់ចិញ្ចឹមគិតជាបរិមាណ (គ,ក្រ ឬ ក្បាល) ក្នុង១ខ្នាត ម៉ែត្រការ៉េផ្ទៃទឹកស្រះ
- បរិមាណត្រីដែលត្រូវដាក់ចិញ្ចឹមអាស្រ័យដោយលក្ខណៈទ្រង់ទ្រាយនៃការចិញ្ចឹម
- តាមបច្ចេកទេសការចិញ្ចឹមត្រីចំរុះ (១-៥ក្បាល/ម$^{២}$ ) ចំពោះការចិញ្ចឹមត្រីបង្ហាញ យើងកំណត់យក ដង់ស៊ីតេ(៣ក្បាល/ម$^{២}$ ) និងមានទំហំសមស្របពី (៥-១០សម)ចិញ្ចឹមពាក់កណ្តាលប្រពលវប្បកម្ម ។

## ៣.៥ ចំនួនកូនត្រីដាក់ចិញ្ចឹម

- គួរដាក់ត្រីចិញ្ចឹមចំរុះទើបប្រសើរជាងការដាក់ត្រីចិញ្ចឹមទោល
- ចំនួនកូនត្រីដាក់ចិញ្ចឹមពី ៖ ៣ក្បាល/ម២ ចិញ្ចឹមបង្ហាញបច្ចេកទេស និងអាចចន្លោះពី ១-៥ក្បាល/ម២
- ប្រភេទត្រីដាក់ចិញ្ចឹមចំរុះ ក្នុងករណីត្រីឆ្ពិនជាប្រភេទសំខាន់ ៖
    - ឆ្ពិន=៥០% ទីឡាព្យា=៤០% កាបសាមញ្ញ /កាបឥណ្ឌា=១០% ឬ
    - ទីឡាព្យា=៥០% ឆ្ពិន=៤០% កាបសាមញ្ញ /កាបឥណ្ឌា=១០%



**សកម្មភាពកសិករដឹកជញ្ជូនកូនត្រីពូជ ដាក់ចិញ្ចឹមក្នុងស្រះ**

## ៣.៦ ទំហំកូនត្រីសមស្រប

- ទីឡាព្យា ៖ ៥សម-៨សម
- កាបឥណ្ឌា ៖ ៨សម-១០សម
- ឆ្ពិន ៖ ៥សម-៨សម
- កាបសាមញ្ញ ៖ ៥សម-៨សម



**ទីឡាព្យាទំហំ ៦សម**



**កូនត្រីកាបឥណ្ឌាទំហំ ៨សម**



**កូនត្រីឆ្ពិនទំហំ ៦សម**

## ៣.៧ ការដាក់ជីក្រោយដាក់ចិញ្ចឹម

ក្រោយពីដាក់កូនត្រីចិញ្ចឹមបានរយៈពេលពី ១០ ទៅ ១៥ ថ្ងៃ យើងត្រូវពិនិត្យមើលទឹកស្រះ ឬមើលចំណីធម្មជាតិក្នុងស្រះ បើពិនិត្យឃើញទឹកស្រះមានពណ៌បៃតងចាស់ មានន័យថាស្រះមានចំណីធម្មជាតិប្លង់តុង តែបើឃើញទឹកស្រះលែងមានពណ៌បៃតង នោះយើងត្រូវបន្ថែមជីដូចខាងក្រោម:

### ៣.៧.១ ជីធម្មជាតិ

- លាមកគោ/ក្របីស្រស់
- លាមកជ្រូក
- មាន់/ទា
- ពពួករុក្ខជាតិបៃតង(ទន្ទ្រាងខែត្រ ផ្ទី សង្កែ កន្ទុំថេត...។

វិធីសាស្ត្រធ្វើជីកំប៉ុស្តធម្មជាតិ មានដូចខាងក្រោម:

#### ៣.៧.១.១ ការជីករណ្ដៅជី

រណ្ដៅត្រូវជីក នៅជ្រុងសងខាងនៃស្រះ ឬទីតាំងណាមួយសមស្រប ដែលងាយស្រួលបង្ហូរទឹកជីចូលទៅក្នុងស្រះ។ រណ្ដៅជីមានទំហំ=១.៥មx២មx០.៨ម អាចធ្វើទៅតាមលទ្ធភាពកសិករ ដូចជា: ជីកជារណ្ដៅ ប្រើពាង លូ/ខ្នោះអណ្ដូងក៏បាន ។ នៅបាតរណ្ដៅត្រូវធ្វើយ៉ាងណាកុំឲ្យទឹកសូលុយស្យុងជ្រាបទៅក្រោមបាន។ ផ្នែកនៃរណ្ដៅជីត្រូវភ្ជាប់ទុយោ ចន្លោះប្រហែល ២ តឹក ពីបាតរណ្ដៅ ដោយមាន វ៉ាន ឬឆ្នុក បិទ/បើក ដើម្បីបង្ហូរទឹកជី/សូលុយស្យុង ទៅក្នុងស្រះ។



**រូបភាពផ្សេងៗ នៃរណ្ដៅជី**

#### ៣.៧.១.២ ការរៀបចំកំប៉ុស្តក្នុងរណ្ដៅជី

មានលាមកគោ/ក្របីស្រស់ ឬលាមកជ្រូក មាន់/ទា ពពួករុក្ខជាតិបៃតង(ទន្ទ្រាងខែត្រ ផ្ទី សង្កែ ...)

- បរិមាណលាមកគោ មាន់ ទា =១០០គក្រ/១០០ម$^{២}$ និង
- បរិមាណរុក្ខជាតិបៃតង (ទន្ទ្រាងខែត្រ ផ្ទី សង្កែ កន្ទុំថេត...) គឺ ៨០គក្រ/១០០ម$^{២}$ ។

សមាសធាតុទាំងអស់នេះដាក់ចូលទៅក្នុងរណ្ដៅដែលបានរៀបចំជាស្រេច រួចចាក់ទឹកជាល្បាយបង្កើតបានជា

ជីកំប៉ុស្ត។ ជាទូទៅគេអាចប្រើប្រាស់វាបានបន្ទាប់ពីផ្អាប់ទុកក្រោយរយៈពេល៧ថ្ងៃ។ ជីកំប៉ុស្តដែលរៀបចំមួយលើកៗ អាចប្រើប្រាស់បានរយៈពេលពី ២០-៣០ថ្ងៃ អាស្រ័យទំហំស្រះ តូច ឬ ធំ។





**រូបភាពផ្សេងៗនៃការរៀបចំរណ្តៅជីកំប៉ុស្ត៍**

### ៣.៧.២ ជីគីមី

ជីគីមីក៏មានសារៈសំខាន់ក្នុងការបង្កើតប្លង់តុង ។ បរិមាណជីគីមីប្រើប្រាស់សំរាប់ស្រះចិញ្ចឹមត្រីគឺៈ

- ជីអ៊ុយរ៉េ ០.៧ គក្រ ក្នុង១០០ម$^{២}$ និង
- ជីដេអាប៉េ ០.៣ គក្រ ក្នុង១០០ម$^{២}$

មុនពេលដាក់ជី ត្រូវលាយ អ៊ុយរ៉េ និង ដេអាប៉េ ជាមួយទឹករួចកូរឲ្យរលាយ ទើបយកទៅបាចឲ្យបានសព្វលើផ្ទៃស្រះទំហំ ១០០ ម៉ែត្រការ៉េ ក្នុងកំឡុងពេល ៣ ទៅ ៥ ថ្ងៃ ក្រោយមកទឹកស្រះនឹងប្រែពណ៌បៃតង។

ត្រូវឧស្សាហ៍បន្ថែមជី តាមបរិមាណខាងលើរៀងរាល់សប្តាហ៍ ដើម្បីរក្សា ទឹកស្រះឲ្យមានពណ៌បៃតងជានិច្ច។

## ៤ ការគ្រប់គ្រងគុណភាពទឹក

ក្រោយពីដាក់កូនត្រីចិញ្ចឹម រយៈពេលពី១០-១៥ថ្ងៃ យើងត្រូវពិនិត្យគុណភាពទឹកស្រះឡើងវិញបើឃើញថាទឹកលែង មានពណ៌បៃតង នោះយើង ត្រូវបន្ថែមជីភ្លាម ដោយ ប្រើរណ្តៅដែលបានរៀបចំទុកជាស្រេច។

### ៤.១ ការពិនិត្យពណ៌ទឹកដោយភ្នែកទទេ

-ទឹកស្រះមានពណ៌បៃតងខ្ចី មានន័យថា កកើតចំណីធម្មជាតិគ្រប់គ្រាន់

-ទឹកស្រះមានពណ៌បៃតងចាស់ មានន័យថា កកើតចំណីធម្មជាតិច្រើនពេក ដូច្នេះត្រូវបញ្ឈប់ការ ដាក់ជីធម្មជាតិមួយរយៈសិន បើមិនដូច្នេះទេនឹងធ្វើឲ្យត្រីពុល ឬងាប់ ។

-ទឹកស្រះល្អក់ដោយសារដី  នោះពុំមានចំណីធម្មជាតិទេ ជាហេតុធ្វើឲ្យត្រីធំធាត់យឺត

-ទឹកថ្លាមានន័យថា ខ្វះចំណីធម្មជាតិ ដូច្នេះត្រូវបន្ថែមជី



**ទឹកពណ៌បៃតងខ្ចី**



**ទឹកពណ៌បៃតងចាស់**



**ទឹកស្រះល្អក់**



**ទឹកស្រះថ្លា**

## ៤.២ ការពិនិត្យគុណភាពទឹកដោយប្រើឧបករណ៍វាស់ pH

គុណភាពទឹកទាក់ទង នឹងប៉ារ៉ាម៉ែត្រសំខាន់ៗជាច្រើនដូចជា៖

- ប៉េហាស (pH)- ប្រើទួនេសុលដើម្បីវាស់ទឹក
- កំរិតរលាយ អុកស៊ីសែន
- កំរិតថ្លាទឹក
- សីតុណ្ហភាព-ប្រើសីតុណ្ហមាត្រ
-

**ប៉េហាស និងប្រសិទ្ធភាព ទៅលើការរស់នៅរបស់ត្រី**

| ប៉េហាស(pH) | ប្រសិទ្ធភាព |
|---|---|
| ៤ | អាស៊ីតខ្លាំង |
| ៤-៦ | ត្រីលូតលាស់យឺត |
| ៦-៩ | ត្រីលូតលាស់ល្អប្រសើរ |
| ៩-១១ | ត្រីលូតលាស់យឺត(រយៈពេលយូរទៅនាំអោយត្រីងាប់ |
| ១១+ | អាល់កាឡាំងខ្លាំង |



**សកម្មភាពកសិករពិនិត្យគុណភាពទឹក និង វាស់ pH ទឹកដោយប្រើក្រដាសទួណឺសុល**

-

## ៤.៣ ការផ្តល់ចំណី

ចំណីមានសារៈសំខាន់ណាស់សំរាប់ការលូតលាស់របស់ត្រី ។ ចំណីមានពីរប្រភេទ: ចំណីធម្មជាតិ និង ចំណីបន្ថែម។ ការលូតលាស់របស់ត្រី គឺអាស្រ័យគុណភាពចំណី និងបរិមាណចំណីដែលផ្តល់ឲ្យត្រី។

### ៤.៣.១ ចំណីធម្មជាតិ

មានដូចជា ប្លង់តុងសត្វ ប្លង់តុងរុក្ខជាតិ និងសត្វរស់នៅស្រទាប់បាត មានខ្យងខ្ចៅជន្លេនក្រហមជាដើម។

ចំណីធម្មជាតិ ពោលគឺកំប៉ុស្តលាមកគោ/ក្របី មាន់/ទា ជ្រូកនិងពពួករុក្ខជាតិបៃតងជាដើម ឬអាចជាចំណីបន្ថែមផងដែរ។ បើកបង្ហូរទឹកជី(សូលុយស្យុង)ដោយផ្ទាល់ចេញពីរណ្តៅជី ឬដងបាចទៅលើផ្ទៃស្រះធ្វើដូចនេះទឹកជីមានល្បាយសព្វពេញស្រះ នៅពេលដែលមានកំដៅថ្ងៃល្អ រយៈពេល ២-៣ ថ្ងៃក្រោយមក ប្លង់តុងសត្វ និង ប្លង់តុងរុក្ខជាតិ បានកកើតពេញស្រះដែលជាចំណីធម្មជាតិសំរាប់ត្រី។







សកម្មភាពកសិករៀបចំជីកំប៉ុស្ត និងបង្ហូទឹកជីចូលក្នុងស្រះចិញ្ចឹមត្រី

## ៤.៣.២ ចំណីបន្ថែម

បានមកពីការផ្សំចំណីច្រើនប្រភេទដូចជា: កន្ទក់ ចុងអង្ករ ម្សៅត្រី ពោត សណ្តែកឬចំណីគ្រាប់ជាដើម ។ ក្រៅពីនេះមានចំណីដែលអាចរកបាននៅក្នុងភូមិមាន ចកបាយទា ពងទឹក កណ្តៀរ ជន្លេន កាកសំណល់ផ្ទះបាយ កាកសំណល់បន្លែ និងកាកសំណល់ពីទីសត្តឃាដ ។ល។

-ផ្តល់ចំណីដែលផ្សំពីកន្ទក់ ម្សៅត្រី ចុងអង្ករ ពោត សណ្តែក ត្រូវចំអិនឲ្យឆ្អិន ទុកឲ្យត្រជាក់រួច ពូតជាដុំ ដាក់ក្នុងកញ្ជ្រែង ហើយពន្លិចក្នុងទឹកជម្រៅ ០.៥ ម៉ែត្រ។

-ការផ្តល់ចំណីត្រីត្រូវកំណត់ទីកន្លែងឱ្យបានច្បាស់លាស់

-បរិមាណចំណីផ្តល់ឲ្យត្រីស៊ី ប្រែប្រួលទៅតាមទំហំរបស់ត្រី គឺពី ៣ ទៅ៥% នៃទំងន់ត្រីសរុបក្នុងស្រះ

-ផ្តល់ចំណីជាទៀងទាត់បរិមាណពី ២០-២៥គក្រ/ស្រះទំហំពី ៣០០-៥០០ម$^{២}$ /ថ្ងៃ នៅចន្លោះម៉ោង ៩-១១ព្រឹក និងពេលរសៀល ចន្លោះពីម៉ោង ៤ ទៅ ៥







សកម្មភាពកសិករៀបចំ ចំណីបន្ថែម  សំរាប់ការចិញ្ចឹមត្រី



ចំណីផ្សំមានកន្ទក់ ចុងអង្ករ ត្រីហាល ត្រកួន



កាកសំណល់ត្រី



កាកដូង

# ៥ តាមដានការលូតលាស់ត្រី

ដើម្បីឲ្យការគ្រប់គ្រងលើ ការចិញ្ចឹមត្រីទទួលបានជោគជ័យ ការតាមដានការលូតលាស់របស់ត្រីជាប្រចាំមានសារៈសំខាន់ណាស់ ដោយ ១ខែបន្ទាប់ពីស្តុកកូនត្រី សកម្មភាពនេះអាចឲ្យយើងដឹង:

- ត្រួតពិនិត្យអំពីជំងឺត្រី
- តាមដានអត្រាលូតលាស់ត្រី គណនាបរិមាណចំណីបន្ថែមដែលត្រូវផ្តល់ ទៅតាមទំហំម៉ាសរបស់ត្រី
- ប៉ាន់ស្មាន/អត្រាគង់វង្សត្រីក្នុងស្រះ

ជាទូទៅការតាមដានការលូតលាស់របស់ត្រីត្រូវធ្វើឡើង មួយខែបន្ទាប់ពីដាក់ត្រីចិញ្ចឹម ពោលគឺត្រូវធ្វើរៀងរាល់ ១ខែម្តង ដើម្បីត្រួតពិនិត្យទៅលើប៉ារ៉ាម៉ែត្រសំខាន់ៗ ដែលទាក់ទងនឹងកត្តាធំធាត់របស់ត្រី នោះគឺ pH នៃទឹក គុណភាពទឹក ជាដើម។ល។

ដើម្បីអនុវត្តតាមដានការលូតលាស់នេះកសិករត្រូវអនុវត្តដូចតទៅ:

## ៥.១ ត្រៀមរៀបចំសំភារៈ

- ឧបករណ៏សំរាប់ចាប់ត្រី- មានថ្នងដង សំណាញ់ អួនសំរាប់កៀរ
- ឧបករណ៏សំរាប់វាស់ ថ្លឹង- បន្ទាត់មានក្រឹត(សង់ទីម៉ែត្រ) ជញ្ជីងទំងន់ (១ ឬ ២ គីឡូក្រាម)
- សៀវភៅកត់ត្រាទិន្នន័យ
- ឧបករណ៏សំរាប់វាស់ pH ទឹក

## ៥.២ ការយកសំណាក និង វាស់ថ្លឹងត្រី

ចាប់ត្រីដោយប្រើឧបករណ៏ខាងលើ សមស្រប នៅទីតាំងខុសៗគ្នា ចំនួន៣កន្លែង នៅតាមស្រះនីមួយៗ ការវាស់ថ្លឹងត្រូវធ្វើលើប្រភេទទាំងបី ទីឡាព្យា ឆ្ពិន និងកាបសាមញ្ញ។ ប្រវែង និងទំងន់ ត្រូវកត់ត្រាចូលក្នុងសៀវភៅឲ្យបានច្បាស់លាស់។

- ការយកគំរូត្រីត្រូវ យកនៅ៣ ទីតាំងខុសៗគ្នា ដែលមួយលើកៗយកពី ១០-២០ត្រីតាមប្រភេទនីមួយៗ
- រៀបចំអួនដាក់ក្នុងទឹកនៅនឹងកែងស្រះជាស្រេច ពេលផ្តល់ចំណី គឺធ្វើលើទីតាំងនោះដែលអាចយើងចាប់ត្រីពីក្នុងសំណាញ់យកមកវាស់ ថ្លឹង។
- ពេលវាស់ ថ្លឹង ក្នុងករណីត្រីមានរោគសញ្ញា ឬជំងឺ ត្រូវយកចេញ ដើម្បីសាកសួរអ្នកជំនាញ


ត្រីឆ្ពិនចិញ្ចឹម២ខែ


ត្រីកាបសាមញ្ញ ចិញ្ចឹម២ខែ


ត្រីទីឡាព្យាចិញ្ចឹម២ខែ

- **តារាងតាមដានការលូតលាស់របស់ត្រី**

| ថ្ងៃខែឆ្នាំ (រៀងរាល់១ខែម្តង) | ប្រភេទត្រី | រយៈពេលចិញ្ចឹម (ថ្ងៃ ឬ ខែ) | ទំងន់ (ក្រាម/ក្បា) | ប្រវែង (សម/ក្បា) | pH ទឹក ៤- ៧ដង/ខែ | ចំណីធម្មជាតិ (គក្រ) | ចំណីបន្ថែម (គក្រ) | កំណត់សំគាល់ |
|---|---|---|---|---|---|---|---|---|
| ថ្ងៃខែឆ្នាំដាក់ត្រីចិញ្ចឹម / /២០១១ | ឆ្ពិន | 0 | | | | | | |
| | ទីឡាព្យា | 0 | | | | | | |
| | កាបសាមញ្ញ | 0 | | | | | | |
| / /២០១១ | ឆ្ពិន | ៣0 | | | | | | |
| | ទីឡាព្យា | ៣0 | | | | | | |
| | កាបសាមញ្ញ | ៣0 | | | | | | |
| / /២០១១ | ឆ្ពិន | | | | | | | |
| | ទីឡាព្យា | | | | | | | |
| | កាបសាមញ្ញ | | | | | | | |
| / /២០១១ | ឆ្ពិន | | | | | | | |
| | ទីឡាព្យា | | | | | | | |
| | កាបសាមញ្ញ | | | | | | | |
| / /២០១១ | ឆ្ពិន | | | | | | | |
| | ទីឡាព្យា | | | | | | | |
| | កាបសាមញ្ញ | | | | | | | |

# ៦ ការប្រមូលផលត្រី និងទីផ្សារ

## ៦.១ ការប្រមូលផលរំលោះ

ជាទូទៅ ការចិញ្ចឹមត្រីក្នុងស្រះ ពិសេសចិញ្ចឹមចំរុះការប្រមូលផលត្រីគឺចាប់ពីរយៈពេល ៨ខែ-១ឆ្នាំ នឹងត្រូវប្រមូលផលយកទៅលក់នៅទីផ្សារ និងប្រើប្រាស់សំរាប់ការហូបក្នុងគ្រួសារ។

ការប្រមូលផលរំលោះ គឺគួរចាប់ផ្តើមដំណើរការ បន្ទាប់ពីចិញ្ចឹមបានរយៈពេល ពី២ ទៅ ៣ ខែ ជាបណ្តើរៗ ដោយឡែកចំពោះការចិញ្ចឹមបង្ហាញបច្ចេកទេស ការចាប់រំលោះគឺ សំដៅលើការដងយកកូនត្រីទិឡាព្យា ចេញយកទៅផ្សាំក្នុងហាប៉ា ឬ ស្រះទុកធ្វើពូជ ជាពិសេសគឺដើម្បី ឲ្យដង់ស៊ីតេស្រះមានទំហំទូលាយសំរាប់ប្រភេទទាំង៣ ឆ្ពិន ទិឡាព្យា និងកាសាមញ្ញ/កាបឥណ្ឌា ការលូតលាស់បានលឿន។

## ៦.២ ការប្រមូលផលសរុប

ការប្រមូលផល ចាប់ផ្តើមបន្ទាប់ពីបានចិញ្ចឹមរយៈពេល៨ ឡើងទៅ ដែលពេលនោះត្រីមានទំហំកាន់តែធំ ជាមធ្យមទំងន់ចាប់ពី ២៥០ក្រាម ទៅ ៣៥០ក្រាម ក្នុងមួយក្បាល អាចយកទៅលក់ក្នុងទីផ្សារបាន និងមានតម្លៃសេដ្ឋកិច្ចខ្ពស់។ ដើម្បីឲ្យការប្រមូលផលសរុបនេះទទួលបានផលចំណេញច្រើននោះ យើងគួរធ្វើឡើងនៅពេល

-ប្រមូលផលត្រីចិញ្ចឹមបានរយៈពេល ពី ៨ ខែឡើងទៅ

-ត្រីទំងន់ចាប់ពី ២៥០ក្រាម ទៅ ៣៥០ក្រាម ក្នុង១ក្បាល

-ប្រមូលផលត្រីនៅរដូវខ្សត់ត្រី ឬរដូវបិទនេសាទ

-ជាពិសេសនៅពេលដែលតម្លៃត្រីនៅទីផ្សារឡើងខ្ពស់

-លក់ឲ្យអ្នកប្រើប្រាស់ក្នុងតំបន់ និងខេត្ត ដើម្បីផ្សព្វផ្សាយលទ្ធផល និងពង្រីកការចិញ្ចឹមត្រី

## ៦.៣ បច្ចេកទេសប្រមូលផល

គួរដំណើរការនៅពេលព្រឹក ពេលដែលលក្ខណបិរស្ថានស្រះល្អ ហើយដើម្បីងាយស្រួលនិងតំលៃទីផ្សារត្រីល្អ ពេលប្រមូលផលត្រូវញែកទំហំត្រីធំ និងតូច ដាក់ដោយឡែកពីគ្នា ងាយស្រួលលក់តាមតម្លៃទីផ្សារ។

- ប្រើអួនអូសក្រឡា១-១.៥សម
- ករណីទឹកនៅជ្រៅអាចបូមទឹកចេញខ្លះដើម្បីងាយស្រួលប្រមូលផល
- ប្រើម៉ាស៊ីនបូមទឹកពង្រីង រួចចាប់ ដោយត្រៀមសំភារៈសំរាប់ទុកដាក់ប្រោះត្រី
- ក្រោយប្រមូលផលហើយកសិករ គួរតែស្តារភក់បាតស្រះ និងជួសជុលស្រះឲ្យបានល្អ ទាន់ពេលដីនៅសើម សំរាប់ការដាក់ត្រីចិញ្ចឹមបន្តទៀត។
-

## តារាងតាមដានទំងន់និងតំលៃទីផ្សារត្រី

| ថ្ងៃខែឆ្នាំ | ប្រភេទត្រី | ទម្ងន់ត្រីជាមធ្យម(ក្រាម/ក្បាល) | ទម្ងន់ត្រីសរុប(គ.ក្រ) | តម្លៃរាយ (រ) | តម្លៃសរុប (រ) |
|---|---|---|---|---|---|
| | ត្រីឆ្ពិន | | | | |
| | កាបសាមញ្ញ /កាបឥណ្ឌា | | | | |
| | ទីឡាព្យា | | | | |
| | | | | | |

## តារាងចំណាយ

| លរ | ថ្ងៃខែឆ្នាំ | ប្រភេទមុខចំណាយ | ចំនួន | តម្លៃ/ឯកត្តា | តម្លៃសរុប | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | បូមទឹកចេញ/ចូលស្រះ | | | | |
| | | ទិញកំបោរ | | | | |
| | | ជី គីមី | | | | |
| | | កូនត្រីពូជ | | | | |
| | | ចំណី | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

## តារាងចំណូល

| លរ | ថ្ងៃខែឆ្នាំ | ប្រភេទមុខចំណាយ | ចំនួន | តម្លៃ/ឯកត្តា | តម្លៃសរុប | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | លក់កូនត្រីទីឡាព្យា | | | | |
| | | ត្រីចាប់ហូប | | | | |
| | | ត្រីឲ្យគេ | | | | |
| | | លក់ត្រីសាច់ | | | | |
| | | ទុកពូជ | | | | |
| | | | | | | |

**ប្រាក់ចំណេញ**(ក្នុងមួយវដ្តនៃការចិញ្ចឹម)= **ចំណូលសរុប - ចំណាយសរុប**